01585152

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D360/3

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស

## អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 09 / 2018
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សំងាត់

## សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អោ អាន៖**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

| | |
|---|---|
| ជេត វណ្ណលី | Laure DESFORGES |
| ហុង គីមសួន | Isabelle DURAND |
| គីម ម៉េងឃី | Emmanuel JACOMY |
| ឡោ ជុនធី | Martine JACQUIN |
| សំ សុគង់ | Daniel MCLAUGHLIN |
| ស៊ិន សុវ៉ន | Lyma NGUYEN |
| ទី ស្រីនណា | Nushin SARKARATI |

01585153



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទទួលបាន "សំណើបន្ទាន់សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន" ដែលសហមេធាវីការពារក្តី អោ អាន ("សហមេធាវីការពារក្តី") បានដាក់កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ ("សំណើសុំ")[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយរបស់គាត់[2] ជាភាសាខ្មែរ ដោយលើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន។ ដោយឡែក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយរបស់គាត់ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)[3] ជាភាសាអង់គ្លេស (ជារួមហៅថា "ដីកាដំណោះស្រាយ")។

២. នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ សហមេធាវីការពារក្តីបានដាក់សំណើសុំជាភាសាអង់គ្លេសសិន ហើយបានដាក់សំណៅជាភាសាខ្មែរនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ស្នើសុំកោសលុបអាសយដ្ឋានរបស់ អោ អាន ចេញពីក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)[4] ហើយបានកត់សម្គាល់បន្ថែមទៀតថា ឈ្មោះរបស់សាក្សីមួយចំនួនដែលត្រូវបានការពារត្រូវបានចេញផ្សាយដោយភាន់ច្រឡំ[5]។

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") សំណើបន្ទាន់សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ដែលបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ និងបានជូនដំណឹងជាភាសាខ្មែរនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360/1 ("សំណើសុំ")។

[2] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន ចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ តែជាភាសាខ្មែរប៉ុណ្ណោះ ឯកសារ D359។

[3] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) ចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ តែជាភាសាអង់គ្លេសប៉ុណ្ណោះ ឯកសារ D360។

[4] សំណុំសុំ កថាខណ្ឌ ១២។

[5] សំណុំសុំ កថាខណ្ឌ ៦។



E.C.C.C. PRE-TRIAL CHAMBER

៣. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះ និងភាគីថា សហព្រះរាជអាជ្ញាពុំមានបំណងឆ្លើយតបទៅនឹងសំណើសុំឡើយ[6]។

៤. នៅថ្ងៃដដែលនោះ ខណៈពេលអង្គបុរេជំនុំជម្រះត្រៀមនឹងចេញដីកាចាត់របៀប សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាតាមឆន្ទានុសិទ្ធិរបស់ខ្លួន [7] បង្គាប់ឲ្យកោសលុបជាបន្ទាន់លើឈ្មោះសាក្សីដែលត្រូវបានការពារនៅក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)[8]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានស្នើសុំឲ្យសហមេធាវីការពារក្ដីដាក់សំណើសុំរបស់ខ្លួនឡើងវិញ ពាក់ព័ន្ធនឹងការចេញផ្សាយអាសយដ្ឋានរបស់ អោ អាន ជូនសហចៅក្រមស៊ើបអង្កេត [9] ដោយពិចារណាឃើញថា អង្គបុរេជំនុំជម្រះពុំទាន់បានទទួលបណ្ដឹងឧទ្ធរណ៍ណាមួយនៅឡើយ ហេតុដូច្នេះ ពុំទាន់មានយុត្តាធិការដោះស្រាយសំណើសុំនេះទេ[10]។

## II. ភាពអាចទទួលយកបាន

៥. សំណើសុំនេះបានដាក់អនុលោមតាមវិធាន ២១ មាត្រា ៩.១ មាត្រា ៩.២ និងមាត្រា ៩.៣ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ")[11] និងមាត្រា ៣.១២ និងមាត្រា ៣.១៤ នៃសេចក្ដីណែនាំអនុ

---

[6] សំណុំរឿង ០០៤/២ អ៊ីមែលដែលការិយាល័យសហព្រះរាជអាជ្ញាផ្ញើជូនអង្គបុរេជំនុំជម្រះ និងភាគី *កម្មវត្ថុ៖ សំណុំរឿង ០០៤/២ - សំណុំបន្ទាន់របស់មេធាវីការពារក្ដី អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន (ឯកសារ D360/1)* ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

[7] សំណុំរឿង ០០៤/២ ដីកាបង្គាប់ឲ្យកោសលុបដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360/2 ("ដីកាបង្គាប់តាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ")។

[8] ដីកាបង្គាប់តាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៦ កថាខណ្ឌ ៩។

[9] ដីកាបង្គាប់តាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៨។

[10] ដីកាបង្គាប់តាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤។

[11] សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី២ ("សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ") មាត្រា ៩.១ មាត្រា ៩.២ និងមាត្រា ៩.៣។

01585155



វត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")[12] ។ សហមេធាវីការពារក្តីសន្និដ្ឋានថា ការិយាល័យសហចៅក្រមស៊ើបអង្កេត *បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ*នៅពេលចេញដីកាដំណោះស្រាយ ហើយអង្គបុរេជំនុំជម្រះគឺជាអង្គជំនុំជម្រះតែមួយគត់ដែលសហមេធាវីការពារក្តីអាចដាក់សំណើសុំបាន[13]។

៦. អង្គបុរេជំនុំជម្រះសូមរំលឹកថា ការិយាល័យសហចៅក្រមស៊ើបអង្កេត *បំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់ហើយ* ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤/០២ ចាប់តាំងពីពេលចេញដីកាដំណោះស្រាយមកម្ល៉េះ[14]។ ទោះបីជាអង្គបុរេជំនុំជម្រះបានទទួលសំណើសុំបច្ចុប្បន្ននេះក៏ដោយ ក៏ការិយាល័យតុលាការផ្សេងទៀតពុំបានទទួលសំណុំរឿងនេះជាផ្លូវការនៅឡើយទេ អនុលោមតាមមាត្រា ៣.១៤ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ ដោយហេតុថា បណ្តឹងឧទ្ធរណ៍ពុំទាន់ឃើញបានដាក់មកនៅឡើយ។ ទោះបីជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះសង្កេតឃើញថា គោលបំណងនៃសំណើសុំបន្ទាន់នេះនឹងគ្មានប្រយោជន៍ ប្រសិនបើពុំបានដោះស្រាយឲ្យបានឆាប់នោះទេ ហើយនៅក្នុងរឿងក្តីនេះ មាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ គួរបកស្រាយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ក្នុងន័យការពារប្រយោជន៍របស់ភាគី។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមានលក្ខណៈសមស្របក្នុងការអនុវត្តយុត្តាធិការដែលខ្លួនទទួលបាន ក្នុងនាមជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលមុនអង្គសេចក្តី និងនៅពេលពុំមានសេចក្តីសម្រេចជាក់លាក់ណាមួយ សម្រេចលើសំណើសុំនេះ ដើម្បីផលប្រយោជន៍នៃយុត្តិធម៌។

៧. យោងតាមសំអាងហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំនេះអាចទទួលយកបាន។

## III. អង្គសេចក្តី

### ក. អំណះអំណាង

---

[12] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក អ.វ.ត.ក/០០១/២០០៧/វិ.លើកទី៨ មាត្រា ៣.១២ និងមាត្រា ៣.១៤។

[13] សំណើសុំ កថាខណ្ឌ ១-២។

[14] សូមមើល ឧ. តុលាការកំពូលព្រហ្មទណ្ឌបារាំង ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០០២ សំណុំរឿង ០១-៨៧១២៣។

៨. សហមេធាវីការពារក្តីស្នើសុំឲ្យអង្គបុរេជំនុំជម្រះ កោសលុបអាសយដ្ឋានផ្ទាល់ខ្លួនរបស់ អោ អាន ចេញពីក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) និងបង្គាប់ឲ្យដកចេញជាបន្ទាន់ពីក្នុងគេហទំព័ររបស់តុលាការ [15] ។ សហមេធាវីការពារក្តីអះអាងថា ការផ្សាយអាសយដ្ឋានរបស់ អោ អាន គឺជាការរំលោភលើសច្ចធារណ៍និរទោស និងសិទ្ធិឯកជនរបស់ជនត្រូវចោទ ហើយវាអាចនាំឲ្យមានការរុកគួនរំខានពីសំណាក់សារព័ត៌មាន ឬ ផ្តល់នូវផលអាក្រក់ជាងនេះទៀតផង[16]។ ទោះបីជាអាសយដ្ឋាននេះធ្លាប់ ឬមិនធ្លាប់ត្រូវបានអ្នកសារព័ត៌មានបង្ហាញឲ្យដឹងពីមុនមកក្តី ក៏ចៅក្រម អ.វ.ត.ក មានកាតព្វកិច្ចក្នុងការការពារសិទ្ធិជាសារវ័ន្តរបស់ អោ អាន និងការសម្ងាត់នៃកិច្ចដំណើរការនីតិវិធី[17]។

៩. សហមេធាវីការពារក្តីសំអាងលើវិធាន ២១ នៃវិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត[18] និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក [19] នៅពេលអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានថ្លឹងថ្លែងតុល្យភាពឲ្យបានត្រឹមត្រូវរវាងផលប្រយោជន៍នៃជនត្រូវចោទ និងផលប្រយោជន៍ផ្សេងទៀត ដែលកំពុងរងផលប៉ះពាល់ ដូចជា តម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងគោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែលរបស់តុលាការជាដើម[20]។ សហមេធាវីការពារក្តីគូសបញ្ជាក់បន្ថែមទៀតថា នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា និងបារាំង វាពុំមែនជាការអនុវត្ត ឬ ច្បាប់ពុំអនុញ្ញាតឲ្យចេញផ្សាយអាសយដ្ឋានទាំងស្រុងរបស់ជនសង្ស័យ ឬ ជនត្រូវចោទនៅក្នុងឯកសារសាធារណៈក្នុងដំណាក់កាលមុនអង្គសេចក្តីនោះទេ[21]។

## ខ. ការពិភាក្សា

---

[15] សំណើសុំ កថាខណ្ឌ ៣, ១២។

[16] សំណើសុំ កថាខណ្ឌ ៤។

[17] *ដូចខាងលើ*។

[18] សំណើសុំ កថាខណ្ឌ ១, ៧-៨។

[19] សំណើសុំ កថាខណ្ឌ ៩-១០។

[20] សំណើសុំ កថាខណ្ឌ ១១។

[21] សំណើសុំ កថាខណ្ឌ ៥ យោងលើ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២១។ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១១។ ច្បាប់បារាំងស្តីពីសេរីភាពសារព័ត៌មាន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៨១ មាត្រា ៣៨។

01585157



១០. អង្គបុរេជំនុំជម្រះសូមរំលឹកថា កិច្ចស៊ើបសួរនៅតែរក្សាការសម្ងាត់រហូតដល់ពេលស៊ើបមូល ដើម្បីការពារសុចរិតភាព និងផលប្រយោជន៍របស់ភាគី[22]។ បន្ថែមពីនេះ អង្គបុរេជំនុំជម្រះយល់អំពីភាពចាំបាច់ នៅពេលសម្រេចលើបញ្ហាទាំងឡាយស្តីពីការធ្វើចំណាត់ប្រភេទឡើងវិញ និងការកោសលុបក្រោយពេលបញ្ចប់កិច្ចស៊ើបសួរ ដើម្បីថ្លឹងថ្លែងផលប្រយោជន៍ផ្សេងៗដែលអាចប៉ះពាល់ រួមទាំង ផលប្រយោជន៍របស់ជនត្រូវចោទ និងជនរងគ្រោះ តម្លាភាពនៃកិច្ចដំណើរការនីតិវិធីដូចមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង និងផលប្រយោជន៍នៃយុត្តិធម៌[23]។

១១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំកោសលុបអាសយដ្ឋានរបស់ អោ អាន នៅក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសិទ្ធិឯកជន ហើយ ជាទូទៅនោះ សិទ្ធិទទួលបានការការពារផលប្រយោជន៍នៃជនត្រូវចោទ ដូចមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។ ទោះបីជាច្បាប់នៅចំពោះមុខ អ.វ.ត.ក ពុំបានចែងយោងច្បាស់អំពីការការពារភាពឯកជន និងកេរ្តិ៍ឈ្មោះក៏ដោយ [24] ក៏អង្គបុរេជំនុំជម្រះទទួលស្គាល់ការព្រួយបារម្ភដែលបានបង្ហាញដោយសហមេធាវីការពារក្តីពាក់ព័ន្ធនឹងផលវិបាកនៃការចេញផ្សាយអាសយដ្ឋានបច្ចុប្បន្នរបស់ អោ អាន ចំពោះសិទ្ធិឯកជនរបស់គាត់[25]។ អង្គជំនុំជម្រះយល់ឃើញបន្ថែមទៀតថា ការកោសលុបចេញពីក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) នូវអាសយដ្ឋានរបស់ជនត្រូវចោទ ដែលពុំមានចែងជាលក្ខខណ្ឌតម្រូវមួយអនុលោមតាមវិធាន ៦៧

---

[22] សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អវតក-កសចស ("សំណើសុំ ០០៤/០១") (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬ តាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D309/2/1/7 ("សាលដីកាលើការកោសលុបដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/០១") កថាខណ្ឌ ៣៦ យោងលើ វិធាន ៥៦ នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០៤/១ (អបជ ៥៦) សេចក្តីសម្រេចលើសំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D313/2 ("សេចក្តីសម្រេចលើការសំណើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសនៅក្នុងសំណុំរឿង ០០៤/០១") កថាខណ្ឌ ៤។

[23] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា ១.២។ សាលដីកាលើការកោសលុបដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ២៧-២៨, ៣៦។ សូមមើលផងដែរ សេចក្តីសម្រេចលើការសំណើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសនៅក្នុងសំណុំរឿង ០០៤/០១ កថាខណ្ឌ ៥។

[24] សាលដីកាលើការកោសលុបដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ៣០។

[25] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៧។

(២) នៃវិធានផ្ទៃក្នុង[26] នឹងពុំមានផលប៉ះពាល់លើផលប្រយោជន៍ផ្សេងទៀតនោះទេ ពោលគឺ ភាពចាំបាច់ក្នុងការធានាតម្លាភាព សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងគោលបំណងនៃការអប់រំ និងកេរ្តិ៍តំណែលរបស់តុលាការ។

១២. យោងតាមសំអាងហេតុខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា វាមានភាពសមស្របក្នុងការបង្គាប់ឲ្យកោសលុបអាសយដ្ឋានរបស់ អោ អាន ចេញពីក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)។

១៣. ចំណុចចុងក្រោយ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាលែងមានយុត្តាធិការលើសំណុំរឿង ០០៤/២ ហើយក៏ដោយក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសំណៅកោសលុបនៃដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) ដើម្បីធានាការពារដល់សាក្សី[27]។ អង្គបុរេជំនុំជម្រះទំនងអាចនៅតែបង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុលោមតាមសេចក្តីសម្រេចរបស់ខ្លួន ធ្វើការកោសលុបបែបនោះដែរ។ អាស្រ័យហេតុនេះ ផ្អែកលើអង្គហេតុដែលបានកើតឡើង អង្គជំនុំជម្រះយល់ស្របលើការកោសលុបឈ្មោះសាក្សីដែលត្រូវបានការពារ។

**យោងតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

- **យល់ស្រប** លើសំណើសុំ។
- **ឯកភាព** ឲ្យកោសលុបឈ្មោះសាក្សីដែលត្រូវបានការពារនៅក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ជូនតាមរយៈដីកាបង្គាប់លេខ D360/2 ដែលបានធ្វើឡើងតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។
- **បង្គាប់** ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតកោសលុបអាសយដ្ឋានរបស់ អោ អាន ចេញពីក្នុងដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) និងចេញ

---

[26] សូមមើលបញ្ជាក់ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៤៣។ សូមមើលផងដែរ ក្រមនីតិវិធីឆ២១ព្រហ្មទណ្ឌបារាំង មាត្រា ១៨៥។

[27] សូមមើលខាងលើ កថាខណ្ឌ ៩។

សំណៅកែប្រែកោសលុបជាសាធារណៈ ក្នុងរយៈពេលពីរថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីសម្រេចនេះ។

- **បង្គាប់** ឲ្យផ្នែកកិច្ចការសាធារណៈដកចេញជាបន្ទាន់នូវសំណៅបច្ចុប្បន្ននៃដីកាដំណោះស្រាយជាសាធារណៈដែលមានការកោសលុប (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D360) ចេញពីក្នុងសារព័ត៌មានរបស់ អ.វ.ត.ក និងដាក់ជំនួសវិញនូវសំណៅកែប្រែកោសលុបជាសាធារណៈដូចបានកំណត់ខាងលើ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៍យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**